# នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ត.ក

ភាគីដាក់ឯកសារ: ក្រុមមេធាវីការពារក្តីលោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៤

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 25-Nov-2014, 15:26
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ (កោសលុប)

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះតុលាការកំពូល:

ចំណាត់ថ្នាក់ប្រភេទឯកសារ:

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

# សំណើរលើកទីបី សុំឲ្យធ្វើការពិចារណា និងទទួលយកភស្តុតាងបន្ថែម ទាក់ទងបណ្តឹងសាទុក្ខ ប្រឆាំងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០២/០១

---

**ដាក់ដោយ:**

**ក្រុមមេធាវីការពារក្តី នួន ជា**

សុន អរុណ

Victor KOPPE

ព្រុំ ផល្លា

សួន វិសាល

លីវ សុវណ្ណា

Joshua ROSENSWEIG
Doreen CHEN
Xiaoyang NIE

**ចម្លងជូន:**

**សហមេធាវីការពារក្តី ខៀវ សំផន**

គង់ សំអុន

Anta GUISSÉ
Arthur VERCKEN

**សហព្រះរាជអាជ្ញា:**

ជា លាង

Nicholas KOUMJIAN

**សហមេធាវី តំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ

Marie GUIRAUD

អនុលោមតាមវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក (“វិធានផ្ទៃក្នុង”) ១០៤(១) និង ១០៨(៧) សហមេធាវីការពារក្ដី នួន ជា (“មេធាវីការពារក្ដី”) សូមដាក់ជូននូវសំណើសុំការពិចារណា និងទទួលយកភស្តុតាងបន្ថែមទាក់ទងនឹងបណ្តឹងសាទុក្ខរបស់ខ្លួន ប្រឆាំងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០២/០១។

## I. ប្រវត្តិនីតិវិធី

### ក. សំណើសុំឱ្យកោះហៅ Rob Lemkin

1. កាលពីថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៣ គឺប៉ុន្មានសប្តាហ៍មុនបញ្ចប់សវនាការ មេធាវីការពារក្តីទទួលបាននូវសារអេឡិចត្រូនិកមួយដែលខ្លួនមិនដែលបានស្នើសុំ ពី Rob Lemkin សហផលិតករខ្សែភាពយន្ត *សត្រូវប្រជាជន* និង *ថ្ងៃមួយនៅទួលពោធិ៍ជ្រៃ* (“សារអេឡិចត្រូនិករបស់ Rob Lemkin”)។ សារអេឡិចត្រូនិកនេះបញ្ជាក់ថា យោងតាមការសម្ភាសន៍ដែល Rob Lemkin បានធ្វើរួមជាមួយ ថេត សម្បត្តិ នោះ បទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ថា បានប្រព្រឹត្តឡើងនៅទួលពោធិ៍ជ្រៃ ‘ត្រូវបានបញ្ជាដោយ រស់ ញឹម [លេខាភូមិភាគពាយ័ព្យ] មិនមែនជាបញ្ជារបស់មជ្ឈិមទេ’ គាត់បានបន្ថែមទៀត គាត់ និង ថេត សម្បត្តិ ប្រមូលបានភស្តុតាងយ៉ាងសំខាន់អំពី “ផែនការរបស់ញឹម”[1]។ នៅព្រឹកថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៣ និងនៅក្នុងសារណាជាលាយលក្ខណ៍អក្សរជាបន្តបន្ទាប់នោះ មេធាវីការពារក្តីព្យាយាមសុំឱ្យ Lemkin មកបង្ហាញខ្លួនក្នុងនាមជាសាក្សី និងសុំឱ្យមានកិច្ចស៊ើបសួរអនុលោមតាមវិធាន ៩៣ នៃវិធានផ្ទៃក្នុង ទៅលើបណ្តាឯកសារសម្ភារៈរបស់ Lemkin[2]។ មេធាវីការពារក្តីបានលើកទឡ្ហីករណ៍ថា ខ្លួនបានព្យាយាមក្នុងពេលកន្លងមក ឱ្យ Lemkin អាចមកបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះ ហើយបានលើកឡើងថា សហព្រះរាជអាជ្ញាបានពឹងផ្អែកយ៉ាងច្រើនលើស្នាដៃរបស់ Lemkin ក្នុងភាពយន្តទាំងពីររឿង ដែលចាត់ទុកថាជាភស្តុតាងបញ្ជាក់អំពីតួនាទី និងការដឹងឮរបស់ នួន ជា ចំពោះឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ ហើយនឹងចាត់ទុកថាជាព័ត៌មានផ្ទាល់អំពីការកាប់សម្លាប់នៅទួលពោធិ៍ជ្រៃ។ សហព្រះរាជ

---

[1] ឯកសារ E294, សំណើសុំទទួលយកភស្តុតាងថ្មី កោះហៅ Rob Lemkin និងចាប់ផ្ដើមការស៊ើបអង្កេត, ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៣, កថាខណ្ឌ ២។

[2] ឯកសារ E1/221/1, “ប្រតិចារឹកកិច្ចដំណើរការនីតិវិធីជំនុំជម្រះ” ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៣, ទំព័រ ៧:៨ ដល់ ១០:១៨។ ឯកសារ E294, សំណើសុំទទួលយកភស្តុតាងថ្មី កោះហៅ Rob Lemkin និងចាប់ផ្ដើមការស៊ើបអង្កេត, ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៣។

អាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី បានជំទាស់ទៅនឹងសំណើ ដែលត្រូវបានបដិសេធដោយអង្គជំនុំជម្រះសាលាដំបូង[3]។

## ខ. សំណើសុំកោះហៅ ហេង សំរិន

2. នៅថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១៣ មេធាវីការពារក្តីបានដាក់សំណើលើកទីប្រាំមួយ និងជាសំណើចុងក្រោយរបស់ខ្លួន សុំឱ្យកោះហៅ ហេង សំរិន មកផ្តល់សក្ខីកម្ម[4]។ សំណើនេះបានសង្ខេបនូវសំណើទាំងប្រាំកន្លងមករបស់មេធាវីការពារក្តីចំពោះបញ្ហានេះ ព្រមទាំងមូលហេតុយ៉ាងច្រើនដែលបង្ហាញថា ហេង សំរិន គឺជាសាក្សីដ៏សំខាន់បំផុតនៅក្នុងសំណុំរឿង ០០២/០១។ មូលហេតុទាំងនេះរួមមាន៖ តួនាទីរបស់ ហេង សំរិន ដែលស្ថិតនៅក្បែកម្រិតកំពូល ក្នុងជួរកងទ័ពភូមិភាគបូព៌ាគិតត្រឹមថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥, ការចូលរួមយ៉ាងសកម្មរបស់គាត់នៅក្នុងការជម្លៀសចេញពីទីក្រុងភ្នំពេញ ក្នុងតួនាទីនេះ ព្រមទាំងលទ្ធភាពខ្ពស់បំផុត ក្នុងការដឹងឮអំពីខ្លឹមសារនៃបញ្ជាដែលចេញដោយមេដឹកនាំភូមិភាគ ពាក់ព័ន្ធនឹងការជម្លៀស, តួនាទីកំពូលរបស់គាត់នៅក្នុងជួរកងទ័ពភូមិភាគបូព៌ា ដែលជាថ្នាក់ក្រោមផ្ទាល់របស់លេខាភូមិភាគបូព៌ា គឺ សោ ភឹម នៅឆ្នាំ១៩៧៨ និងចម្លើយរបស់គាត់ក្នុងកិច្ចសម្ភាសន៍ជាមួយ Ben Kiernan ដែលថា ការបង្គាប់របស់ នួន ជា គឺ មិនមែនឱ្យសម្លាប់មេដឹកនាំរបបសាធារណរដ្ឋខ្មែរនោះទេ គឺឱ្យដកពួកគេចេញពី "ក្របខ័ណ្ឌ"។ ទោះបីជាចៅក្រមអន្តរជាតិសម្រេចថា ហេង សំរិន គួរត្រូវបានកោះហៅក៏ដោយ ក៏ចៅក្រមជាតិគាត់បានជំទាស់[5]។ ហេង សំរិន មិនដែលមកបង្ហាញខ្លួននោះឡើយ។

## គ. សារណាបញ្ចប់ការពិភាក្សាដេញដោលរបស់មេធាវីការពារក្តី ក្នុងសវនាការ និងសាលក្រមសំណុំរឿង ០០២/០១

3. នៅថ្ងៃទី ២៦ ខែ កញ្ញា ២០១៣ មេធាវីការពារក្តីបានដាក់សារណាបញ្ចប់ការពិភាក្សាដេញដោល

[3] ឯកសារ E294/1, "សេចក្តីសម្រេចលើសំណើរបស់នួន ជា សុំទទួលយកភស្តុតាងថ្មី ចាប់ផ្តើមការស៊ើបអង្កេត និងកោះហៅ Rob Lemkin", ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៣។

[4] ឯកសារ E236/5/1/1, "សំណើលើកទីប្រាំមួយ និងចុងក្រោយ សុំឱ្យកោះហៅសាក្សី TCW 223", ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១៣។

[5] ឯកសារ E312, សេចក្តីសម្រេចស្តាពរស្តីពីសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវស្តាប់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០១,ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤, កថាខណ្ឌ ១០២ ដល់១១១។

របស់ខ្លួន ក្នុងសំណុំរឿង ០០២/០១ ("សារណាបញ្ចប់ការពិភាក្សាដេញដោល")[6]។ ចំណុចគន្លឹះរបស់មេធាវីការពារក្តីគឺថា "មជ្ឈិមបក្ស" នៅក្នុងទីក្រុងភ្នំពេញ ប្រើប្រាស់ការត្រួតត្រាប្រកបដោយប្រសិទ្ធភាព ក្នុងកម្រិតមួយមានកំណត់តែប៉ុណ្ណោះ ចំពោះកម្មាភិបាល នៅក្នុងឋានៈនុក្រមនៃបក្សកុម្មុយនីស្តកម្ពុជា។ ពាក់ព័ន្ធជាពិសេសចំពោះសំណើបច្ចុប្បន្ននេះ មេធាវីការពារក្តីសូមលើកទឡ្ហីករណ៍ថា មេដឹកនាំភូមិភាគ ដូចជា សោ ភឹម និង រស់ ញឹម គឺជាសមាជិកដ៏មានអំណាចក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍ ដែលប្រើប្រាស់សិទ្ធិអំណាចដោយឯករាជ្យយ៉ាងច្រើន ដែលប៉ុល ពត និង នួន ជា មិនងាយនឹងជ្រៀតជ្រែកបានឡើយ។ មេធាវីការពារក្តីបានបន្ថែមបន្តទៀតថា ថ្នាក់ដឹកនាំបក្សខ្លះ បានបង្កើនសិទ្ធិអំណាចរបស់ខ្លួនដើម្បីរួមគំនិតក្បត់ ប៉ុល ពត នួន ជា គឺប្រហែលជាតាំងពីរយៈពេលដំបូងនៃរបបកម្ពុជាប្រជាធិបតេយ្យម្ល៉េះ។ ការប្រឆាំងនេះត្រូវបានគាំទ្រយ៉ាងខ្លាំងក្លាពីសំណាក់រដ្ឋាភិបាលវៀតណាម ហើយប្រហែលជាជាប់ពាក់ព័ន្ធនឹងសម្ព័ន្ធមិត្តរវាង សោ ភឹម និង រស់ ញឹម[7]។

4. នៅថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសសាលក្រមរបស់ខ្លួនក្នុងសំណុំរឿង ០០២/០១ ដោយសម្រេចពីពិរុទ្ធភាពរបស់ នួន ជា ចំពោះគ្រប់បទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ ហើយសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារ នួន ជា អស់មួយជីវិត ("សាលក្រម")[8] ។ សាលក្រមបានសម្រេចថា រចនាសម្ព័ន្ធបក្សកុម្មុយនីស្តកម្ពុជា ជា"ឋានានុក្រមយ៉ាងម៉ឺងម៉ាត់" ហើយកម្មាភិបាលក្នុងបក្សទាំងមូល ស្ថិតក្រោមការគ្រប់គ្រងយ៉ាងម៉ត់ចត់របស់ថ្នាក់ដឹកនាំបក្ស[9]។ សាលក្រមបានសម្រេចបន្ថែមទៀតថា ថ្នាក់ដឹកនាំភូមិភាគ ដូចជាសោ ភឹម និង រស់ ញឹម បានអនុវត្តដោយស្មោះត្រង់តាមការណែនាំពី "ថ្នាក់ដឹកនាំ" បក្ស ហើយ "រាយការណ៍" និងទទួលការបង្គាប់ពី ប៉ុល ពត និង នួន ជា[10]។ អង្គជំនុំជម្រះបានច្រានចោលលទ្ធភាពដែលថា "មេដឹកនាំភូមិ

[6] ឯកសារ E295/6/3, "សារណាបញ្ចប់ការពិភាក្សាដេញដោលរបស់ នួន ជា ក្នុងសំណុំរឿង ០០២/០១" ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣។

[7] ឯកសារ E295/6/3, "សារណាបញ្ចប់ការពិភាក្សាដេញដោលរបស់ នួន ជា ក្នុងសំណុំរឿង ០០២/០១" ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣, កថាខណ្ឌ ១៨០ ដល់១៨៧, ៤៣៥ ដល់៤៣៧។ ប្រតិចារឹកថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៣ (សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល, ឯកសារ E1/232.1), ទំព័រ ២៣ ដល់២៥។

[8] ឯកសារ E313, "សាលក្រមលើសំណុំរឿង ០០២/០១" ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ ("សាលក្រម")។

[9] *សូមមើលជាឧទាហរណ៍* សាលក្រម កថាខណ្ឌ ២២៣, ៩១៣។

[10] *សូមមើលជាឧទាហរណ៍* សាលក្រម កថាខណ្ឌ ២៧៦, ៧៧៣, ៧៩៨, ៨៥១, ៨៩៣, ៩៥៦។

ភាគ" បានធ្វើសកម្មភាពដោយឯករាជ្យ ដើម្បីប្រព្រឹត្តឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់[11]។

## ឃ. សំណើសុំកោះហៅ ថេត សម្បត្តិ

5. នៅថ្ងៃទី ១២ និងទី ១៣ ខែ សីហា ឆ្នាំ ២០១៤ ថេត សម្បត្តិ បានផ្តល់កិច្ចសម្ភាសន៍ចំនួនពីរភាគជាមួយវិទ្យុវីអូអេ ជាភាសាខ្មែរ ("កិច្ចសម្ភាសន៍")។ នៅក្នុងកិច្ចសម្ភាសន៍ ថេត សម្បត្តិ បានបញ្ជាក់ថា គាត់ និង Lemkin បានសម្ភាសន៍មនុស្សជាច្រើនដែលបានបដិសេធមិនផ្តល់ភស្តុតាងជូនសហចៅក្រមស៊ើបអង្កេត ដោយសារតែពួកគាត់ខ្លាចត្រូវគេ "សម្លាប់" ដោយ "អ្នកដឹកនាំនៅក្នុងរដ្ឋាភិបាល"[12]។ ថេត សម្បត្តិ បានអះអាងថា ការសម្ភាសន៍ទាំងនេះ បង្ហាញថាការសម្លាប់ទាហានសាធារណរដ្ឋខ្មែរនៅទួលពោធិ៍ជ្រៃ មិនមែន"ផ្តួចផ្តើមគំនិត" ដោយ នួន ជា ទេ ប៉ុន្តែដោយមនុស្សដែល "នៅក្នុងរដ្ឋាភិបាល [...] អ្នកអស់ហ្នឹងនៅរស់"[13]។ ផ្អែកលើមូលដ្ឋាននេះ ថេត សម្បត្តិ បានរិះគន់យ៉ាងខ្លាំងទៅលើសាលក្រមដែលសម្រេចពីពិរុទ្ធភាពរបស់ នួន ជា ចំពោះបទឧក្រិដ្ឋដែលបានចោទប្រកាន់ថាបានប្រព្រឹត្តនៅទួលពោធិ៍ជ្រៃ។ បន្ថែមលើនេះ ថេត សម្បត្តិ បានបញ្ជាក់ថា ការសម្ភាសន៍ទាំងនេះបង្ហាញថា កម្មាភិបាលនៅទូទាំងរចនាសម្ព័ន្ធរបស់បក្សកុម្មុយនីស្តកម្ពុជា "និយាយទៅគឺភាគច្រើនណាស់ទៅហើយ ដែលក្បត់ប្រឆាំងនឹង ប៉ុល ពត និង នួន ជា។ នៅថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៤ មេធាវីការពារក្តីបានដាក់សំណើទៅអង្គជំនុំជម្រះសាលាដំបូង សូមទទួលយកកិច្ចសម្ភាសន៍ ជាភស្តុតាង ព្រមទាំងកោះហៅ ថេត សម្បត្តិ និង Rob Lemkin មកផ្តល់សក្ខីកម្ម និងស្នើសុំទទួលយកភស្តុតាងដែលពួកគេមាន ("សំណើសុំឱ្យទទួលយកភស្តុតាងបន្ថែមលើកទីមួយ"[14]។

[redacted]

[redacted]

---

[11] សាលក្រម, កថាខណ្ឌ ៨៥៩ ដល់៨៦០។

[12] ឯកសារ F2 "សំណើសុំឱ្យទទួល និងពិចារណាទៅលើភស្តុតាងបន្ថែមទាក់ទងនឹងបណ្តឹងសាទុក្ខ ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង នៅក្នុងសំណុំរឿង ០០២/០១", ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៤, កថាខណ្ឌ ៦។

[13] ឯកសារ F2 "សំណើសុំឱ្យទទួល និងពិចារណាទៅលើភស្តុតាងបន្ថែមទាក់ទងនឹងបណ្តឹងសាទុក្ខ ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង នៅក្នុងសំណុំរឿង ០០២/០១", ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៤, កថាខណ្ឌ ៦។

[14] ឯកសារ F2 "សំណើសុំឱ្យទទួល និងពិចារណាទៅលើភស្តុតាងបន្ថែមទាក់ទងនឹងបណ្តឹងសាទុក្ខ ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង នៅក្នុងសំណុំរឿង ០០២/០១", ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៤។

[redacted]

---

15 [redacted]

[redacted]

[redacted]

[redacted]

## II. ភស្តុតាងបន្ថែម

7. ភស្តុតាងបន្ថែមរួមមានកំណត់ហេតុស្តាប់ចម្លើយ [redacted]

8. [redacted]។ គាត់កើតនៅឆ្នាំ [redacted] ហើយបានចូលបក្សកុម្មុយនីស្តកម្ពុជា នៅក្រោយរដ្ឋប្រហារខែ មីនា ឆ្នាំ ១៩៧០ តាមការអំពាវនាវពីសម្តេចសីហនុ។ ជាដំបូងគាត់គឺជានិរសារនៅភូមិភាគពាយ័ព្យ ហើយរាយការណ៍ជូន រស់ ញឹម លេខាភូមិភាគ។ នៅឆ្នាំ ១៩៦០ គឺនៅពេលដែលគាត់មានអាយុ[redacted]ឆ្នាំ រស់ ញឹម ក្លាយជា[redacted][20]។

9. ក្នុងនាមជា[redacted]របស់ រស់ ញឹម [redacted] បានក្លាយជា[redacted]ដែលរាយការណ៍ជូនថ្នាក់ដឹកនាំភូមិភាគពាយ័ព្យ[21]។ ក្រោយខែ មេសា ឆ្នាំ ១៩៧៥ [redacted]ត្រូវបានតែងតាំងជា[redacted]ភូមិភាគពាយ័ព្យ។ ក្នុងតួនាទីនេះ គាត់ [redacted]។ [redacted]គាត់[redacted] បង្ហាញពីការដឹងឮយ៉ាងទូលំទូលាយរបស់គាត់អំពីបុគ្គលិក រចនាសម្ព័ន្ធចាត់តាំង និងហេតុការណ៍

---

[redacted]

នានានៅក្នុងភូមិភាគពាយ័ព្យ[23]។

10. យោងតាម[redacted]នៅខែ មករា ឆ្នាំ ១៩៧៦ [redacted]។ [redacted] ត្រូវត្រលប់មកប្រទេសកម្ពុជាវិញនៅខែ វិច្ឆិកា ឆ្នាំ ១៩៧៧ ហើយគាត់បានបដិសេធមិនបន្តការសិក្សានៅ[redacted]ដែលផ្ទុយពីបំណងរបស់ រស់ ញឹម។ [redacted] បាននិយាយប្រាប់ថា រស់ ញឹម ខឹងយ៉ាងខ្លាំង ហើយតម្រូវឲ្យគាត់ធ្វើការងារតូចទាបជាច្រើនដូចជា ធ្វើជី និងបើកឡាន ហើយគាត់ក៏បានធ្វើការងារទាំងអស់នេះអស់ជាច្រើនខែ[25]។

11. [redacted] បានប្រាប់[redacted]ថា ក្នុងខែ មេសា ឆ្នាំ ១៩៧៨ គាត់បានរត់គេចចូលព្រៃ ពេលមានការបោសសម្អាត ភូមិភាគពាយ័ព្យ និងបូព៌ា[26]។ ទោះបីជាគាត់បានអះអាងថាគាត់នៅឆ្ងាយពីរបបកម្ពុជាប្រជាធិបតេយ្យ ឬក៏បានបំពេញកិច្ចការតូចតាចតាំងពីចុងឆ្នាំ ១៩៧៥ ក្តី [redacted] បានរៀបរាប់ពីការដឹកនាំកងទ័ពចំនួន ២000 នាក់ចូលទៅក្នុងព្រៃ ហើយបានបញ្ជាកងទ័ពទាំងនោះ ក្នុងពេលប្រយុទ្ធជាមួយកងទ័ពភូមិភាគនិរតី នៅដើមខែ ឧសភា ឆ្នាំ ១៩៧៨[27]។ [redacted] និងកងទ័ពរបស់គាត់ បានប្រើប្រាស់អាវុធ ២0.000 ដើម ដែលគាត់ប្រមូលបានពីទាហានលន់ នល់ ហើយបានយកទៅលាក់ទុកក្នុងឃ្លាំងមួយក្នុងឆ្នាំ ១៩៧៥ គឺមុនពេលចាកចេញទៅ[redacted]។ [redacted] បានបញ្ជាក់ថា ក្រោយពេល សោ ភឹម ត្រូវបានចាប់ខ្លួន[29] ក្នុងខែ ឧសភា ឆ្នាំ ១៩៧៨ រស់ ញឹម បានសុំឲ្យគាត់, [redacted], [redacted]។ [redacted] បានបញ្ជូនកងការពារ [redacted]ទៅឲ្យ រស់ ញឹម ហើយបន្ទាប់មកបានជំរុញឲ្យ រស់ ញឹម ចូលរួមជាមួយគាត់ និងកងទ័ពរបស់គាត់នៅ

---

[redacted]

ក្នុងព្រៃ[31]។ [redacted] បានអះអាងថា បានបង្កើត "ក្រុម" មួយប្រឆាំងប៉ុល ពត នៅពេលមួយក្នុងឆ្នាំ ១៩៧៨ ហើយគាត់បានអះអាងថា បានគ្រប់គ្រងលើតំបន់ចំនួនប្រាំមួយ ក្នុងចំណោមតំបន់ទាំងប្រាំពីរ ក្នុងភូមិភាគពាយ័ព្យ។ គាត់ក៏បានរៀបរាប់ពីការទាក់ទង និងបានជួបប្រជុំជាមួយកងទ័ពរបស់ ហេង សំរិន ដែលគាត់ដឹងថា ហេង សំរិន នឹងធ្វើការវាយប្រយុទ្ធប្រឆាំងទីក្រុងភ្នំពេញ[32]។

## III. ច្បាប់ជាធរមាន

### ក. ការទទួលយកភស្តុតាងថ្មី លើបណ្តឹងសាទុក្ខ

12. ក្នុងក្របខ័ណ្ឌ អ.វ.ត.ក ការទទួលយកភស្តុតាងថ្មី លើបណ្តឹងសាទុក្ខ ស្ថិតក្រោមការគ្រប់គ្រងដោយវិធាន ១០៤(១) និង ១០៨(៧) នៃវិធានផ្ទៃក្នុង។ អនុលោមតាមវិធាន ១០៤(១) "អង្គជំនុំជម្រះតុលាការកំពូលខ្លួនឯង អាចបើកការពិនិត្យលើភស្តុតាង និងស្វែងរកភស្តុតាងថ្មី ដើម្បីធ្វើការសម្រេចលើបញ្ហានេះ"។ វិធាន ១០៨(៧)ចែង ត្រង់ផ្នែកពាក់ព័ន្ធថា៖

> ភាគីអាចស្នើសុំបន្ថែមភស្តុតាងចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល យោងតាមវិធាន ៨៧(៣) បើសិនជាភស្តុតាងនោះមិនអាចរកបានក្នុងពេលសវនាការ ហើយដែលអាចជាកត្តាកំណត់នាំឱ្យឈានដល់ការធ្វើសេចក្តីសម្រេចនៅក្នុងសវនាការ។ សេចក្តីស្នើសុំបន្ថែមភស្តុតាងត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់អំពីទំនាក់ទំនងដោយផ្ទាល់រវាងភស្តុតាងបន្ថែមថ្មីនោះ ជាមួយនឹងសំអាងហេតុជាក់លាក់ដែលអង្គជំនុំជម្រះសាលាដំបូងបានលើក ។

13. អង្គជំនុំជម្រះ ក្នុងពេលកន្លងមកបានប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួន ក្នុងការទទួលយកភស្តុតាងថ្មីអនុលោមតាមវិធាន ១០៨(៧) ពាក់ព័ន្ធទៅនឹងបណ្តឹងសាទុក្ខ ដែលបានដាក់ប្រឆាំងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០១[33]។

---

[redacted]។

[33] សំណុំរឿង ០១/១៨ -០៧-២០០៧ -អវតក /អជតក, ព្រះរាជអាជ្ញា តទល់នឹង កាំងហ្គេកអ៊ាវ, ឯកសារ F2/5/1, "សេចក្តីសម្រេចលើសំណើបន្ថែមរបស់សហមេធាវី តំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី១ សុំឱ្យទទួលយកភស្តុតាងបន្ថែម", ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១១, ERN 00657389-00657391។ សំណុំរឿង ០១/១៨ -០៧-២០០៧ -អវតក /អជតក, ព្រះរាជអាជ្ញា តទល់នឹង កាំងហ្គេកអ៊ាវ, ឯកសារ F2/4, "សេចក្តីសម្រេចលើសំណើរបស់សហមេធាវីតំណាងជនជាប់ចោទ និងដើមបណ្តឹងរដ្ឋ

## IV. ឧទ្ធីករណ៍

[redacted]

[redacted]

### ខ. ភស្តុតាងរបស់ [redacted] គឺមានសារៈសំខាន់ខ្លាំងចំពោះបណ្តឹងសាទុក្ខប្រឆាំងសាលក្រម

<u>i. [redacted] គឺជាសាក្សីដ៏សំខាន់ទាក់ទងទៅនឹងទួលពោធិ៍ជ្រៃ</u>

15. នៅក្នុងសាលក្រម អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា បញ្ជាសម្លាប់ឃោធា និងមន្ត្រីរដ្ឋការសាធារណរដ្ឋខ្មែរ ត្រូវបានចេញដោយ រស់ ញឹម ទៅកងទ័ព និងកម្មាភិបាលស៊ីវិលថ្នាក់តំបន់ នៅប៉ុន្មានថ្ងៃក្រោយពេលរំដោះខេត្តពោធិ៍សាត់[34]។ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា បញ្ជានេះត្រូវបានអនុវត្តនៅសាលាខេត្តពោធិ៍សាត់ និងនៅទួលពោធិ៍ជ្រៃ។ បន្ថែមលើនេះ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា បញ្ជានេះបង្កើតបានជាការអនុវត្ត គោលនយោបាយសហឧក្រិដ្ឋកម្មរួម ដែលបានអនុម័តដោយរស់ ញឹម និង នួន ជា រួមជាមួយអ្នកដទៃទៀត “ដើម្បីកំណត់គោលដៅចំពោះគ្រប់សមាសភាទាំងអស់ ពីអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ដើម្បីចាប់ខ្លួន និង/ឬ

---

ឬវេណីក្រុម ១ ក្រុម ២ និងក្រុម ៣ សុំឱ្យទទួលយកភស្តុតាងបន្ថែម”, ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១១, ERN 00656514-00656517។

[34] សាលក្រម, កថាខណ្ឌ ៦៦៣ ដល់៦៦៦។

ធ្វើឲ្យបាត់ខ្លួន"[35]។

16. ភស្តុតាងដែលអង្គជំនុំជម្រះពឹងផ្អែកសម្រាប់សេចក្តីសន្និដ្ឋានទាំងនេះ គឺមានកម្រិតកំណត់ និងមិនចំទាល់តែសោះ។ ភស្តុតាងតែមួយគត់ដែលថា ការបញ្ជាឲ្យសម្លាប់ទាហានសាធារណរដ្ឋខ្មែរ ត្រូវបានចេញដោយគណៈភូមិភាគ គឺជាភស្តុតាងដែលផ្តល់ឲ្យសហចៅក្រមស៊ើបអង្កេត ដោយកងទ័ពធម្មតាម្នាក់ឈ្មោះ លឹម សាត។ លឹម សាត មិនត្រឹមតែមិនមែនជាសាក្សីផ្ទាល់ នៃការបញ្ជានោះប៉ុណ្ណោះទេ គាត់ថែមទាំងដកចេញនូវសក្ខីកម្មរបស់គាត់ត្រង់ចំណុចនេះទៀត នៅពេលដែលគាត់មកបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[36]។ មិនមានភស្តុតាងស្តីពីការប្រជុំ ឬការទំនាក់ទំនងរវាង "មជ្ឈិមបក្ស" (ដែលមិនមានបែបនេះនោះទេ មុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥) និងកម្មាភិបាលភូមិភាគពាយ័ព្យ ក្នុងអំឡុងពេលវេលាពាក់ព័ន្ធនោះទេ។ មិនមានភស្តុតាងនៃការប្រជុំ និងការទំនាក់ទំនងរវាង រដ្ឋបាល ឬរចនាសម្ព័ន្ធយោធា ភូមិភាគពាយ័ព្យ ក្នុងអំឡុងពេលវេលាពាក់ព័ន្ធនោះទេ។ មិនមានកម្មាភិបាលភូមិភាគពាយ័ព្យសំខាន់ណាម្នាក់ មកផ្តល់សក្ខីកម្មក្នុងសវនាការសំណុំរឿង ០០២/០១ទេ។

17. ផ្ទុយទៅវិញ [redacted] អះអាងថា [redacted] ភូមិភាគពាយ័ព្យ នៅពេលដែលឧក្រិដ្ឋកម្មនៅទួលពោធិ៍ជ្រៃ ត្រូវបានចោទប្រកាន់ថាត្រូវបានប្រព្រឹត្តឡើង។ គាត់មានទំនាក់ទំនងផ្ទាល់ខ្លួន និងទំនាក់ទំនងការងារយ៉ាងជិតស្និទ្ធបំផុតជាមួយ រស់ ញឹម។ សឹងតែប្រាកដណាស់ថា [redacted] បានដឹងថាតើ រស់ ញឹម បានចេញបញ្ជាឲ្យសម្លាប់ទាហាន និងអ្នករដ្ឋការនៅទួលពោធិ៍ជ្រៃ ហើយប្រសិនបើដូច្នេះ គឺគាត់ដឹងថាតើបញ្ជានេះត្រូវបានចេញនៅពេលណា ហើយតើបញ្ជានេះត្រូវបានផ្សព្វផ្សាយដោយរបៀបណា តើបញ្ជានេះមានវិសាលភាពយ៉ាងដូចម្តេច និងសំខាន់បំផុតគាត់ដឹងថាតើបញ្ជានេះចេញពីគណៈអចិន្ត្រៃយ៍ ឬពី នួន ជា និង ប៉ុល ពត ហើយនិងត្រឹមកម្រិតណា។ សក្ខីកម្មដែលអាចជឿទុកចិត្តបានរបស់ [redacted] ចំពោះបញ្ហាណាមួយក្នុងចំណោមបញ្ហាទាំងអស់នេះ នឹងលុបលើតម្លៃភស្តុតាង នៃភស្តុតាងដែលមានស្រាប់នៅក្នុងកំណត់ហេតុ បើទោះបីជាខ្លឹមសារនៃសក្ខីកម្មនោះមានលក្ខណៈបែបណាក៏ដោយ។

ii. [redacted] គឺជាសាក្សីដ៏សំខាន់ ពាក់ព័ន្ធនឹងរចនាសម្ព័ន្ធបក្សកុម្មុយនីស្តកម្ពុជា

[35] សាលក្រម, កថាខណ្ឌ ៨២៩។

[36] សាលក្រម, កថាខណ្ឌ ៦៦៥។

18. ភស្តុតាងរបស់ [redacted] បើទោះប្រសិនបើគាត់បំផ្លើសបន្តិចក៏ដោយ គឺភាពសំខាន់ដូចគ្នា ចំពោះបញ្ហាធំពាក់ព័ន្ធដល់រចនាសម្ព័ន្ធបក្សកុម្មុយនីស្តកម្ពុជា និងទំនាក់ទំនងរវាងថ្នាក់ដឹកនាំភូមិភាគពាយ័ព្យ និង ប៉ុល ពត និង នួន ជា។ [redacted] ទទួលស្គាល់ថា បានចូលរួមយ៉ាងសកម្មក្នុងសកម្មភាពប្រឆាំងរបស់ភូមិភាគពាយ័ព្យ ប្រឆាំងនឹង ប៉ុល ពត ហើយតាមពិតទៅគាត់បានអះអាងថាគាត់បានដឹកនាំសកម្មភាពនេះ។ គាត់បានរៀបរាប់យ៉ាងច្បាស់ពីទំនាក់ទំនងជាមួយកងទ័ពរបស់ ហេង សំរិន ក្នុងពេលជម្លោះរវាងពួកគេ ជាមួយកងទ័ពភូមិភាគនិរតី និងមជ្ឈិមបក្ស។ ហេតុដូច្នេះ ភស្តុតាងរបស់គាត់បន្ថែមទម្ងន់ដល់សារណារបស់មេធាវីការពារក្តី ដែលបានលើកឡើងក្នុងសារណាបញ្ចប់ការពិភាក្សាដេញដោល ហើយដែលត្រូវបានបំភ្លេចចោលក្នុងសាលក្រម គឺថាបុគ្គលដឹកនាំក្នុងភូមិភាគពាយ័ព្យ និងភូមិភាគបូព៌ា បានបង្កើតជាក្រុមប្រឆាំងរួមគ្នា ប្រឆាំងនឹងប៉ុល ពត។

19. ចំណុចសំខាន់គឺ [redacted] បានរៀបរាប់ថាបានផ្តួចផ្តើមជម្លោះប្រដាប់អាវុធជាចំហរដោយផ្ទាល់នេះតាំងពីឆ្នាំ ១៩៧៥ មកម្ល៉េះ។ ក្នុងនាមជា [redacted] ភូមិភាគពាយ័ព្យ [redacted] បានរៀបរាប់ពីការប្រមូលផ្តុំគ្រឿងសព្វាវុធទ្រង់ទ្រាយធំ ដែលមានអាវុធចំនួន ២០.000 ដើម ពីទាហានសាធារណរដ្ឋខ្មែរ ដែលបានចុះចាញ់ ហើយបានលាក់អាវុធទាំងអស់នេះក្នុងឃ្លាំងមួយ។ ដោយសារតែតួនាទីរបស់គាត់នៅក្នុងជួរកងទ័ពភូមិភាគ និងទំនាក់ទំនងផ្ទាល់ខ្លួនរបស់គាត់ជាមួយ រស់ ញឹម គឺប្រហែលបំផុតដែលថា គាត់ធ្វើសកម្មភាពតាមបញ្ជារបស់ រស់ ញឹម ឬដោយមានការយល់ព្រម និងគាំទ្រដោយ រស់ ញឹម។ ប៉ុន្តែមិនមានលទ្ធភាពទាល់តែសោះ ក្នុងការស្ទង់មើលពីមូលហេតុដែលកម្មាភិបាលស្មោះត្រង់ជាមួយ ប៉ុល ពត នៅក្នុងរចនាសម្ព័ន្ធ “រាងពីរ៉ាមីត” ដែលមាន “ឋានានុក្រមតឹងរ៉ឹង” បែរជាព្យាយាមលាក់បាំងហេតុការណ៍មិនអាចទាយទុកនេះ មិនឱ្យមជ្ឈិមបក្សដឹង។ ដោយផ្អែកលើចម្លើយ ការសន្និដ្ឋានដ៏សមហេតុផលតែមួយគត់គឺថា អាវុធទាំងអស់នេះត្រូវរក្សាទុកពិសេសសម្រាប់គោលដៅដែលពួកគេត្រូវប្រើប្រាស់នៅចុងក្រោយ៖ គឺក្នុងសភាពការណ៍ទុំជោរដែលជម្លោះកាន់តែកើនឡើងបន្តិចម្តងៗ រវាងក្រុមដែលប្រជែងគ្នានៅក្នុងបក្ស។

20. ឯកសារនៅក្នុងសំណុំរឿងគាំទ្រដល់ភស្តុតាងរបស់ [redacted] លើបញ្ហានេះ។ សៀវភៅរបស់ ថេត សម្បត្តិ មានចំណងជើងថា *Behind the Killing Fields* បង្ហាញពីបទសម្ភាសន៍របស់គាត់ជាច្រើនជាមួយកម្មាភិបាលរដ្ឋបាល និងយោធារបស់ភូមិភាគពាយ័ព្យដែលដឹងអំពីគម្រោងការបះបោលប្រ

ឆាំងនឹង ប៉ុល ពត និង នួន ជា នៅចាប់តាំងពីដើមឆ្នាំ ១៩៧៦មកម្ល៉េះ[37]។ តួនាទីរបស់ វស់ ញ៉ឹម ក្នុងការប្រឆាំងនេះត្រូវបានរៀបរាប់ជាពិសេស។ បុគ្គលពីររូបគឺជាមន្ត្រីយោធា រួមទាំង [redacted] ដែលជាមេបញ្ជាការកងពល និងជា [redacted] គឺទំនងណាស់ក្នុងការដឹងអំពីរឿងនេះ។ វត្តមានរបស់ [redacted] ក្នុងការបញ្ជាក់អំពីបញ្ហានេះ គឺសំខាន់ណាស់ដល់ការការពារក្តីរបស់ នួន ជា។

21. លក្ខណៈពិសេសមួយទៀតនៃ [redacted] គឺការចោទសួរដ៏សំខាន់ពីសច្ចភាពរបស់លំដាប់លំដោយនៃហេតុការណ៍ ដែលគាត់បានរៀបរាប់។ [redacted] បានអះអាងថា បានកាត់ផ្តាច់ចេញពីសកម្មភាពដឹកនាំនៅក្នុងភូមិភាគពាយ័ព្យ ពីខែ មករា ឆ្នាំ ១៩៧៦ នៅពេលដែលគាត់បានចាកចេញទៅ [redacted]។ គាត់បានបញ្ជាក់ថា បន្ទាប់ពីគាត់ត្រឡប់មកប្រទេសកម្ពុជាវិញ ក្នុងខែ វិច្ឆិកា ឆ្នាំ ១៩៧៧ កម្មាភិបាលផ្សេងបានកាន់កាប់តំណែងរបស់គាត់ នៅក្នុងឋានានុក្រមភូមិភាគពាយ័ព្យ[38]។ ប៉ុន្តែបើយោងតាមចម្លើយរបស់ [redacted] នៅក្នុងខែ មេសា ឆ្នាំ ១៩៧៨ គាត់មានលទ្ធភាពចាប់ផ្តើមបញ្ជាភ្លាមៗឡើងវិញ ទៅលើកងទ័ពជាង ២០០០នាក់ ហើយនឹងគ្រប់គ្រងទៅលើអាវុធជាង ២០.០០០ ដើម។ ត្រឹមខែ ឧសភា គាត់មានអំណាចយ៉ាងខ្លាំង រហូតដល់ថ្នាក់ វស់ ញ៉ឹម សុំឱ្យគាត់ [redacted]។ ភ្លាមៗនោះ [redacted] អាចគ្រប់គ្រងទៅលើភូមិភាគពាយ័ព្យសឹងតែទាំងស្រុង។

22. យ៉ាងហោចណាស់ ក៏ការអះអាងទាំងអស់នេះទាមទារឱ្យមានការពន្យល់បន្ថែមដែរ។ ហេតុអ្វីបានជា [redacted] បដិសេធមិនត្រឡប់ទៅ [redacted] នៅ ខែវិច្ឆិកា ឆ្នាំ ១៩៧៧? តើគាត់ធ្វើបែបណាទើបអាចក្លាយទៅជាមេដឹកនាំនៃក្រុមប្រឆាំងដ៏សំខាន់របស់បក្សកុម្មុយនីស្តកម្ពុជា ដោយមិនមានការត្រៀមរៀបចំ ឬការធ្វើផែនការជាមុន ក្រោយពេលជិតពីរឆ្នាំកន្លះដែលគាត់នៅឆ្ងាយពីមេដឹកនាំភូមិភាគ? តើមានអ្នកដទៃផ្សេងទៀតក្នុងភូមិភាគបានដឹងអំពីអាវុធដែលបានរក្សាទុកដែរឬទេ? តើ [redacted] តែម្នាក់ឯង ធ្វើយ៉ាងណាអាចប្រមូលគ្រប់គ្រងអាវុធទាំងអស់នោះបាន? តើ [redacted] ធ្វើយ៉ាងណា

---

[37] ឯកសារ **E3/4202**, 'Behind the Killing Fields: A Khmer Rouge Leader and one of his Victims', ERN 00757531-2 (ពីពណ៌នាអំពីបទសម្ភាសន៍ជាមួយ អ៊ិន ធឿន ចាន់ សរុធ និង ជាល ឈឿន)។

[38] [redacted] បាននិយាយជាបន្តបន្ទាប់មកទៀតថាគាត់ "អាចបាន"ត្រឡប់មកពីប្រទេសចិនវិញ នៅពាក់កណ្តាលឆ្នាំ ១៩៧៧។ សូមមើល [redacted] នៅទំព័រ ៣៨។ ភាពមិនច្បាស់លាស់នេះចាំបាច់ត្រូវមានការបញ្ជាក់ និងអាស្រ័យហេតុនេះហើយគឺចាំបាច់ត្រូវមានវត្តមានរបស់គាត់ក្នុងការផ្តល់សក្ខីកម្ម។ សូមមើល កថាខណ្ឌ ២២ ខាងលើ។

ទើបមានអំណាចខ្លាំង រហូតដល់ រស់ ញឹម ខ្លួនគាត់ផ្ទាល់ត្រូវបង្ខំចិត្ត សុំឱ្យគាត់[redacted] តើ [redacted]ចូលរួមដែរឬទេក្នុងសកម្មភាពនានា ចន្លោះខែ មករា ឆ្នាំ ១៩៧៦ ដល់ ខែ មេសា ឆ្នាំ ១៩៧៨ ដែលទាំងរូបគាត់ ឬមេកើយរបស់គាត់នៅក្នុងរដ្ឋាភិបាល មិនចង់ពិភាក្សា?

**គ. [redacted]គួរត្រូវបានទទួលយកអនុលោមតាមវិធាន ១០៨(៧) នៃវិធានផ្ទៃក្នុង**

23. វិធាន ១០៨(៧) នៃវិធានផ្ទៃក្នុងបានគិតគូរយ៉ាងច្បាស់លាស់ពីសំណើសុំដាក់ភស្តុតាងបន្ថែម នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល ក្នុងករណីដែលភស្តុតាងបែបនេះ “មិនអាចរកបាននៅពេលជំនុំជម្រះ”។ [redacted]។ ហេតុដូច្នេះ ឯកសារនេះមិនអាចរកបាននៅពេលសវនាការ។

24. វិធាន ១០៨(៧) ក៏តម្រូវផងដែរថា ភស្តុតាងបន្ថែម “ដែលអាចជា”កត្តាកំណត់នាំឱ្យឈានដល់ការធ្វើសេចក្ដីសម្រេចនៅក្នុងសវនាការ។ [redacted]បានគាំទ្រដល់ការអះអាងយ៉ាងសំខាន់របស់មេធាវីការពារក្ដី នួន ជា ដែលត្រូវបានបដិសេធដោយអង្គជំនុំជម្រះសាលាដំបូង នៅក្នុងសាលក្រម ហើយដែលជាចំណុចស្នូលនៃការវាយតម្លៃលើការទទួលខុសត្រូវព្រហ្មទណ្ឌ។ កំណត់ហេតុស្ដាប់ចម្លើយនេះបង្ហាញថា ប៉ុល ពត និង នួន ជា ត្រូវបានប្រឆាំងដោយក្រុមមួយនៅក្នុងបក្ស ដែលរួមមានសម្ព័ន្ធមិត្តរវាងកម្មាភិបាលជាន់ខ្ពស់ នៅក្នុងភូមិភាគបូព៌ា និងភូមិភាគពាយ័ព្យ។ កំណត់ហេតុស្ដាប់ចម្លើយបង្ហាញថា ការរៀបចំផែនការយ៉ាងម៉ត់ចត់ និងលួចលាក់ សម្រាប់ការប៉ះទង្គិចដោយអាវុធជាមួយ ប៉ុល ពត និង នួន ជា យ៉ាងហោចណាស់ក៏ចាប់ផ្ដើមតាំងពីឆ្នាំ ១៩៧៥ មកម្ល៉េះ។ ហើយឯកសារក៏បង្ហាញផងដែរថា កម្មាភិបាលថ្នាក់ភូមិភាគ បានធ្វើសេចក្ដីសម្រេចសំខាន់ៗ ដូចជាការកសាងឃ្លាំងអាវុធ ផ្ទុកអាវុធ ២០.០០០ដើម ហើយលាក់បាំងមិនឱ្យប៉ុល ពត និង នួន ជា ដឹង ដែលទាំង ប៉ុល ពត និង នួន ជា មិនបានយល់ព្រមនោះទេ។ ហេតុដូច្នេះ សេចក្ដីសម្រេច (ដែលមិនមានសំអាងស្រាប់ទៅហើយនោះ) របស់អង្គជំនុំជម្រះ ក្នុងការដកចេញនូវលទ្ធភាពដែលថា មេដឹកនាំភូមិភាគ អាចធ្វើសកម្មភាពដោយឯករាជ្យមិនចំណុះមជ្ឈិមបក្ស ឬផ្ទុយនឹងការណែនាំរបស់មជ្ឈិមបក្សនោះ ត្រូវបានបង្ហាញថារឹតតែមិនមានមូលដ្ឋានការពារបានទៅទៀត។

25. សារៈសំខាន់នៃ[redacted] រិតតែបង្ហាញច្បាស់តាមរយៈការបញ្ជាក់បន្ថែមនៃភស្តុ

តាងដែលបង្ហាញដោយមេធាវីការពារក្តី នៅក្នុងសំណើសុំដាក់ភស្តុតាងបន្ថែមលើកទីមួយរបស់ខ្លួន[39]។ ថេត សម្បត្តិ និង Rob Lemkin បានអះអាងថាមានភស្តុតាងដែលបង្ហាញថា ការសម្លាប់នៅទួលពោធិ៍ជ្រៃ មិនមែនផ្តួចផ្តើមឡើងដោយមជ្ឈិមបក្សទេ ប៉ុន្តែដោយកម្មាភិបាលថ្នាក់ភូមិភាគ ដែលធ្វើតាម "ផែនការរបស់ [រស់] ញឹម"។ កម្មាភិបាលទាំងនោះ បាន "ប្រឆាំង" និង "ក្បត់" ប៉ុល ពត និង នួន ជា ហើយបច្ចុប្បន្ននេះគឺជាអាជ្ញាធរដែលមានឥទ្ធិពលគ្រប់គ្រាន់ "ក្នុងរដ្ឋាភិបាល" ដែលសាក្សីភ័យខ្លាចថាខ្លួនអាច "ត្រូវគេសម្លាប់" ប្រសិនបើខ្លួនផ្តល់សក្ខីកម្ម។ ការអះអាងទាំងអស់នេះ ត្រូវគ្នានឹងខ្លឹមសារនៃ [redacted]។

**ឃ. [redacted] គួរត្រូវបានទទួលយក ហើយត្រូវកោះហៅ [redacted] អនុលោមតាមវិធាន ១០៤(១)**

26. ការបង្ហាញខ្លួនរបស់ [redacted] មកផ្តល់សក្ខីកម្ម និងសួរដេញដោល លើបណ្តឹងសាទុក្ខ គឺជាការសំខាន់ផងដែរ។ ទោះបីជា [redacted] គឺជាសាក្សីដ៏សំខាន់ជាងគេ ពាក់ព័ន្ធការចោទប្រកាន់ពីហេតុការណ៍នៅទួលពោធិ៍ជ្រៃ ជាងអ្នកដទៃដែលមកផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឬចំពោះមុខសហចៅក្រមស៊ើបអង្កេតក្តី [redacted] មិនបានយោងទៅលើការប្រព្រឹត្តិចំពោះ អ្នករដ្ឋការសាធារណរដ្ឋខ្មែរ សាលាខេត្តពោធិ៍សាត់ ឬទួលពោធិ៍ជ្រៃឡើយ។ ក្រៅពី ហេង សំរិន ប្រហែលជាគាត់គឺជាបុគ្គលដែលនៅមានជីវិតតែម្នាក់ ដែលមេធាវីការពារក្តីបានដឹងថាប្រហែលជាមានព័ត៌មានផ្ទាល់ ដែលអាចធ្វើការសម្រេចដោយផ្ទាល់ពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ នួន ជា ចំពោះការចោទប្រកាន់ពីហេតុការណ៍នៅទួលពោធិ៍ជ្រៃ។ បន្ថែមលើនេះ កំណត់ហេតុស្តាប់ចម្លើយរបស់ [redacted] បង្ហាញថាគាត់គឺជាសាក្សីដែលល្អបំផុតសម្រាប់ធ្វើការវិនិច្ឆ័យលើការការពារក្តីដ៏ទូលំទូលាយជាគន្លឹះរបស់ នួន ជា នៅក្នុងផ្នែកទាំងពីរ នៃសំណុំរឿង ០០២៖ គឺបក្សកុម្មុយនីស្តកម្ពុជាគឺជាបក្សដែលមានការបែកបាក់យ៉ាងជ្រាលជ្រៅ នៅកម្រិតកំពូលរបស់ខ្លួន ព្រោះមេដឹកនាំបក្សខ្លះ ដែលក្នុងចំណោមពួកគេ គឺ [redacted] បានប្រឆាំងនឹងមេដឹកនាំដែលល្បី ក្នុងជម្លោះដណ្តើមអំណាចយ៉ាងជូរចត់។ ចំពោះហេតុផលទាំងពីរនេះ មេធាវីការពារក្តីនឹងធ្វើការស្វះស្វែងរកយ៉ាងខ្លាំងក្លាពីសក្ខីកម្មរបស់ [redacted] នៅដំណាក់ជំនុំជម្រះ ប្រសិនបើខ្លួនបានដឹងពីអត្ថិភាពរបស់ [redacted]។

27. ដូចដែលចៅក្រមអន្តរជាតិ នៃអង្គបុរេជំនុំជម្រះបានសម្រេចរួចហើយ ការមិនកោះហៅសាក្សី

[39] សូមមើល កថាខណ្ឌទី៥ ខាងលើ។

ដែលស្នើឡើងដោយជនជាប់ចោទ នឹងរារាំងពួកគេ "មិនឲ្យទទួលបានផលប្រយោជន៍ដែលអាចមាន ដែលអាចទទួលបានពីសក្ខីកម្មបែបនេះ"[40]។ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចប្រហែលគ្នានេះថា ការមិនកោះហៅសាក្សីគន្លឹះនឹងប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទ ក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ ដែល"ភស្តុតាងដោះបន្ទុកអាចត្រូវបានរារាំងដោយមិនត្រឹមត្រូវក្នុងពេលសវនាការ"[41]។ ថាតើនេះជាការពិតដែរឬយ៉ាងណានោះ គឺអាស្រ័យលើ "ថាតើមេធាវីការពារក្តីទទូចស្នើសុំឲ្យមានភស្តុតាងដែរឬយ៉ាងណា នៅក្នុងសំណើរបស់ខ្លួន ថាតើសំណើសុំនេះអាចទទួលយកបានដែរឬយ៉ាងណាតាមវិធាន ៨៧ នៃវិធានផ្ទៃក្នុង ថាតើអង្គហេតុដែលកើតចេញពីសក្ខីកម្ម រងការជំទាស់ដែរឬយ៉ាងណា ថាតើសាក្សីដែលត្រូវបានកោះហៅនោះ បង្ហាញខ្លួនដែរឬយ៉ាងណា ហើយប្រសិនបើពុំបានធ្វើដូច្នោះវិញ ថាតើអង្គហេតុទទួលបានពីសាក្សីដែលបានកោះហៅមកផ្តល់សក្ខីកម្មនោះ អាចមានលក្ខណៈខុសគ្នាដែរឬយ៉ាងណា[42]។ ការសម្រេចនេះស៊ីសង្វាក់គ្នានឹងការអនុវត្តជាអន្តរជាតិ ដែលទទួលស្គាល់ថា ក្នុងករណីដែលភស្តុតាងដោះបន្ទុកដែលមានភាពពាក់ព័ន្ធ ត្រូវបានច្រានចោលដោយមិនសមស្រប ក្នុងដំណាក់កាលជំនុំជម្រះ ពេលនោះសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌របស់ជនជាប់ចោទ តម្រូវឲ្យមានការបង្ហាញខ្លួនសាក្សីនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល[43]។

28. ទោះបីថាសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ និងអង្គជំនុំជម្រះតុលាការកំពូល ទាំងពីរនេះ ពាក់ព័ន្ធដល់ ហេង សំរិន ក៏ដោយ តែក៏សមស្របដូចគ្នាចំពោះ [redacted]។ ដោយសន្មតថាអត្តសញ្ញាណរបស់ [redacted] [redacted] គឺជាអត្តសញ្ញាត្រឹមត្រូវនោះ គាត់ជាមួយ វស់ ញឹម គឺដូចគ្នានិង ហេង សំរិនជាមួយ សោ ភឹម៖ គឺជាអនុប្រធានដ៏ស្មោះ

[40] ឯកសារ D314/1/12 , មតិយោបល់របស់ចៅក្រម Catherine Marchi-Uhel និងចៅក្រម Rowan Downing ក្នុងសាលដីកាលើកទីពីរលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី និងលោក នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស លើសំណើសុំឲ្យកោះហៅសាក្សី ចុះថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១០, កថាខណ្ឌ ១២។

[41] ឯកសារ E116/1/7 សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ, ចុះថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១២, កថាខណ្ឌ ៣២។

[42] ឯកសារ E116/1/7 សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ, ចុះថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១២, កថាខណ្ឌ ៣២។

[43] *រដ្ឋអាជ្ញា តទល់នឹង Theneste Bagosora និង Anatole Nsengiyumva,* ICTR-98-41-A, "សាលក្រម", ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១១, កថាខណ្ឌ ៥៣២ ដល់ ៥៣៣។

ត្រង់ដែលមានតួនាទីអាចដឹងឮគ្មានគេប្រៀប នៅពេលដែលមានការប្រព្រឹត្តិឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ក្នុងសំណុំរឿង ០០២/០១ ហើយដែលក្រោយមកធ្វើការវាយប្រយុទ្ធប្រឆាំងប៉ុល ពត និង នួន ជា បន្ទាប់ពីមេកើយរបស់ខ្លួនបានផ្តាច់ខ្លួនចេញ។ ដោយសារហេតុផលទាំងអស់នេះហើយ ទើបភស្តុតាងរបស់ [redacted] ដូចនឹងភស្តុតាងរបស់ ហេង សំរិន គឺពិតជាសំខាន់ខ្លាំងណាស់ចំពោះកិច្ចដំណើរការនីតិវិធី។

[redacted]

30. ទោះជាយ៉ាងនេះក្តី ភស្តុតាងរបស់ [redacted] គឺសំខាន់យ៉ាងច្បាស់ក្រឡែតចំពោះសំណុំរឿង ០០២/០១។ មេធាវីការពារក្តីសូមកត់សម្គាល់ថា [redacted] ត្រឹមតែប៉ុន្មានសប្តាហ៍ប៉ុណ្ណោះ មុនពេលភាគីនានាក្នុងសំណុំរឿង ០០២ បង្ហាញទឡ្ហីករណ៍យ៉ាងសន្ធឹកសន្ធាប់ នៅចំពោះមុខអង្គជំនុំ

---

[redacted]

ជម្រះសាលាដំបូង ពាក់ព័ន្ធគោលនយោបាយភូមិភាគពាយ័ព្យ ចំពោះអ្នករដ្ឋការ និងយោធាសាធារណរដ្ឋខ្មែរ។ ទំនាក់ទំនងរបស់ រស់ ញឹម ជាមួយ ប៉ុល ពត និង នួន ជា រួមទាំងចេតនា និងសមត្ថភាពរបស់គាត់ក្នុងការអនុវត្តដោយឯករាជ្យ ឬផ្ទុយពីបញ្ជារបស់ ប៉ុល ពត និង នួន ជា គឺជាចំណុចគន្លឹះនៃការខ្វែងយោបល់គ្នារវាងភាគីនានា។ ការដែលសហចៅក្រមស៊ើបអង្កេតមិនបាន [redacted] ពាក់ព័ន្ធការចោទប្រកាន់ក្នុងសំណុំរឿង ០០២ បានបង្កជាការព្រួយបារម្ភថ្មីអំពីភាពពេញលេញនៃកិច្ចស៊ើបអង្កេតក្នុងសំណុំរឿង ០០២ និងជាពិសេសថា តើមានការផ្តល់ការពិចារណាគ្រប់គ្រាន់ដែរឬទេ ចំពោះការទទួលខុសត្រូវរបស់កម្មាភិបាលជាន់ខ្ពស់ ក្នុងឋានានុក្រមបក្សកុម្មុយនីស្តកម្ពុជា ក្រៅពីជនជាប់ចោទ ចំពោះឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ក្នុងសំណុំរឿង ០០២[46]។

[redacted]

---

[redacted]

[redacted]

[redacted] [redacted]

---

[redacted]

។

[redacted]

[redacted]

[redacted] [redacted]

## V. សេចក្តីសន្និដ្ឋាន និងសំណើសុំដំណោះស្រាយ

34. មេធាវីការពារក្តីស្នើសុំ

ក. ទទួលយកជាភស្តុតាង នូវ[redacted]

[redacted] [redacted]

[51] សូមមើលកថាខណ្ឌ ១ ដល់ ៥, ១៧ ដល់ ២៣ ខាងលើ។

ខ. កោះហៅ [redacted] មកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល និង

គ. [redacted]

**សហមេធាវីរបស់ នួន ជា**

**សុន អរុណ** **Victor KOPPE**